ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៥៧/២៩-៨-២០១១
សាលដីកា
លេខ ០៧ ក្រ.III "ណ"/០៩-៤-១២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២៦-៣-២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៥៧ ចុះថ្ងៃទី ២៩-៨-២០១១ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

**-ជនជាប់ចោទ ៖**

**១-ឈ្មោះ** [redacted] **ទើត** ភេទប្រុស អាយុ ២៩ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិព្រៃឆ្លង ឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ទីលំនៅមុនពេលចាប់ខ្លួន [redacted] ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ (ឃុំខ្លួននៅពន្ធនាគារខេត្តព្រៃវែង)។

មានលោក [redacted] ហួឡាយ ជាមេធាវីការពារក្តី ។

**២-ឈ្មោះ** [redacted] **ហើម** ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិព្រៃឆ្លង ឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ (ឃុំខ្លួននៅពន្ធនាគារខេត្តព្រៃវែង)។

មានលោក [redacted] ហួឡាយ ជាមេធាវីការពារក្តី ។



Scanned with CamScanner

**ជាប់ចោទពីបទៈ** ប្លន់ ប្រព្រឹត្តនៅភូមិជាត់សណ្ដោង ឃុំញ្ញ ១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង កាលពីថ្ងៃទី ០២-៦-២០១០ ។ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្ដឹងរដ្ឋប្បវេណី ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ៥០ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិជាត់សណ្ដោង ឃុំញ្ញ ១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

២-ឈ្មោះ [redacted] ភេទស្រី អាយុ ៣១ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិជាត់សណ្ដោង ឃុំញ្ញ ១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

<u>ឯរឿងហេតុមានដូចតទៅ</u>

**បានឃើញ**ពាក្យបណ្ដឹង ចុះថ្ងៃទី ០២-៦-២០១០ របស់ឈ្មោះ [redacted] សុំប្ដឹងពីចោរមួយក្រុមដែលមានគ្នា ០៣ នាក់ ចូលមកគាស់ទ្វារផ្ទះរបស់ពួកខ្លួន និងសម្លុតគំរាមកំហែងយកប្រាក់អស់ចំនួន ៤០០.០០០ រៀល, ជញ្ជៀនផ្កាទីន ០២ វង់ ទម្ងន់ ០១ ជី, ក្រវិលមាស ០១ គូរ ទម្ងន់ ០១ ជី និងទូរស័ព្ទដៃ ០១ គ្រឿង ហើយក្រុមចោរបានវាយដំពួកខ្លួនឲ្យរងរបួសយ៉ាងធ្ងន់ធ្ងរ ។ ក្នុងរឿងនេះ ខ្លួនសូមទាមទារសំណង និងថ្លៃព្យាបាលរបួសផង ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ១៩ "ក" ព្រ.ទ ចុះថ្ងៃទី ១០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ឲ្យឈ្មោះ [redacted] នី ដែលមានសាវតាជាតិដូចខាងលើ និងឈ្មោះ [redacted] ជៀម ដែលមានសាវតាជាតិដូចខាងលើ រួចផុតពីបទចោទ សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅភូមិជាត់សណ្ដោង ឃុំញ្ញ ១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង កាលពីថ្ងៃទី ០២-៦-២០១០ ។ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្ដន្ទាទោស ៖

-ឈ្មោះ [redacted] វ៉េត ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគាររយៈពេល ០៦ ឆ្នាំ (ប្រាំមួយឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៥-៦-២០១០ ។

-ឈ្មោះ [redacted] ហើម ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគាររយៈពេល ០៦ ឆ្នាំ (ប្រាំមួយឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៥-៦-២០១០ ។

ពីបទៈ ប្លន់ ប្រព្រឹត្តនៅភូមិជាត់សណ្ដោង ឃុំញ្ញ ១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង កាលពីថ្ងៃទី ០២-៦-២០១០ ។ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-វត្ថុតាង សំបកគ្រាប់ចំនួន ០៩ គ្រាប់ មានលេខដូចខាងក្រោម ៖

-លេខ ៩៥ ចំនួន ០៥ សំបក

-លេខ ៧១ ចំនួន ០២ សំបក

-លេខ ៩៣ ចំនួន ០១ សំបក

១៤០

Scanned with CamScanner

-លេខមើលមិនច្បាស់ ០១ សំបក

សម្រេចរឹបអូសបំផ្លាញចោល ។

៤-បង្គាប់ឲ្យឈ្មោះ [redacted] វ៉េត និងឈ្មោះ [redacted] ហើម រួមគ្នាសងសំណងចំនួន ០១ លាន ០៥ សែន រៀល ឲ្យទៅឈ្មោះ [redacted] ជា និងឈ្មោះ [redacted] ចាន្ទី ជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលសាលក្រមចូលជាស្ថាពរតទៅ ។

៥-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២១-៤-២០១១ និងថ្ងៃទី ១០-៦-២០១១ ប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី ២៣-៦-២០១១ សម្រេចចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉េត, ឈ្មោះ [redacted] ហើម, ឈ្មោះ [redacted] នី, ឈ្មោះ [redacted] ជៀម និងចំពោះមុខជនរងគ្រោះឈ្មោះ [redacted] និងឈ្មោះ [redacted] ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៩ ចុះថ្ងៃទី ២៨-៦-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉េត និងឈ្មោះ [redacted] ហើម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩ "ក" ព្រ.ទ ចុះថ្ងៃទី ១០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង លើចំណុចនៃសាលក្រមទាំងមូល ។

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី ៣០-១១-២០១១ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១៩-១២-២០១១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វ៉េត ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាដំបូងខេត្តព្រៃវែង ដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ ។ ខ្លួនចេញពីភ្នំពេញទៅលេងផ្ទះប្អូនស្រី ហើយពេលយប់បានចេញទៅផ្លុះកង្កែបនៅវាលក្រោយផ្ទះ រួចវិលមកដេកផ្ទះប្អូនវិញ គឺមិនបានដឹងសមត្ថកិច្ចចុះទៅបង្ក្រាបអ្វីទេ លុះព្រឹកឡើងសមត្ថកិច្ចបានមកចាប់ឃាត់ខ្លួនតែម្តង ។

ក្រៅពីទៅផ្លុះកង្កែប គឺខ្លួនមិនបានដើរទៅណាទេ នៅយប់នោះ ខ្លួននៅដេកផ្ទះរហូត មិនបានដឹងថា សមត្ថកិច្ចចុះទៅបង្ក្រាបផង ។ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយដើមបណ្តឹងទេ តែប្អូនរបស់ខ្លួនធ្លាប់មានជម្លោះជាមួយដើមបណ្តឹងកន្លងមកអំពីរឿងបិតច្រកផ្លូវមិនឲ្យដើរ ។ ខ្លួនផ្លុះកង្កែបប្រហែលកន្លះម៉ោងបានកង្កែប ២-៣ ក៏វិលមកផ្ទះមើលទូរទស្សន៍ មើលដល់ម៉ោងប្រហែល ១១ យប់ ទើបចូលដេករហូតទល់ភ្លឺ ។ នៅក្នុងផ្ទះដែលខ្លួនដេកនោះ មានឪពុក-ម្តាយ, ប្អូនស្រី និងក្មួយៗ ។ ខ្លួនចេញពីផ្ទះឪពុកនៅភូមិព្រៃឆ្លងទៅដល់ផ្ទះប្អូននៅភូមិជាត់សណ្តោងម៉ោង ៥ ល្ងាច គឺទៅជាមួយប្រពន្ធ និងកូនខ្ចី ។ ពីផ្ទះដែលខ្លួនដេកទៅផ្ទះកើតហេតុនោះ មានចម្ងាយប្រហែល ២០ ម ហើយផ្ទះនៅម្តុំនោះមានច្រើនដែរ ដោយឃ្លាតគ្នាប្រហែល ១០ ម ឬ ២០ ម គឺនៅពីមុខពីក្រោយគ្នា និងមានរបងឬស្សី ។ ក្នុងរឿងនេះ ខ្លួនសំណូមពរសុំតុលាការដោះលែងខ្លួនឲ្យមានសេរីភាពវិញ ។



Scanned with CamScanner

**-ជនជាប់ចោទឈ្មោះ [redacted] ហើម** ឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសអ្វីទេ, នៅយប់នោះ ខ្លួនទៅឆ្លុះកង្កែបជាមួយបងនៅវាលក្រោយផ្ទះ រួចហើយវិលមកដេកផ្ទះវិញ ដោយមិនបានចេញទៅណាទៀតទេ គឺមានឪពុក-ម្តាយ និងបងប្អូនជាអ្នកដឹងឮ ។ ខ្លួនមិនដឹងថា មានចោរចូលប្របាច់ ក យកលុយ និងមាសនោះទេ ព្រោះពេលខ្លួនត្រឡប់មកពីឆ្លុះកង្កែបវិញ ក៏បានដេកលក់ហ្មត គឺមិនបានដឹងថា មានសមត្ថកិច្ចទៅបង្ក្រាប ឬព័ទ្ធចាំចាប់ចោរឡើយ ។

កាលពីមុនបងរបស់ខ្លួនបានសុំផ្លូវគេ (ដើមបណ្តឹង) ដើរចេញ-ចូល តែក្រោយមកគេបានបិតផ្លូវនោះវិញ ហើយក៏កើតមានទំនាស់គ្នា ។ ការឆ្លុះកង្កែបនោះ គឺឆ្លុះនៅលើគោក តាមភ្លឺស្រែ កាលនោះ មានភ្លៀងនៅពេលថ្ងៃ តែពេលយប់ពុំមានភ្លៀងទេ ។ ខ្លួនឆ្លុះកង្កែបនោះ គឺយកសាង (ស្នូ) ទៅចាក់ មិនមែនចាប់ដោយដៃទេ ។ ក្នុងរឿងនេះ ខ្លួនសំណូមពរសុំតុលាការដោះលែងខ្លួនឲ្យមានសេរីភាពវិញ ។

**-ក្រឡាបញ្ជីអានរបាយការណ៍សំយោគលេខ** ២១/១០ រ.ប.ក ចុះថ្ងៃទី ០៤-៦-២០១០ របស់អធិការដ្ឋាននគរបាលស្រុកស៊ីធរកណ្តាល ។

**-តំណាងមហាអយ្យការសន្និដ្ឋានថា** ពាក់ព័ន្ធនឹងរឿងនេះ យើងបានស្តាប់រួចហើយក្នុងពេលសវនាការនេះ តាមអង្គហេតុត្រូវបានជនជាប់ចោទបដិសេធចោលទាំងអស់ ដោយពុំមានអ្វីសំអាងទេ ប៉ុន្តែរឿងនេះ តំណាងមហាអយ្យការយល់ឃើញថា ពាក់ព័ន្ធនឹងក្រុមចោរប្រដាប់អាវុធ ហើយបន្ទាប់ពីក្រឡាបញ្ជីអានរបាយការណ៍សំយោគរបស់នគរបាលរួចមក យើងគួរកត់សំគាល់ទាំងអស់គ្នាថា នៅក្រោយពេលកើតហេតុមានចោរស្រែកថា នៃរ៉ឺយសភាពការណ៍មិនស្រួលទេ រីឯជនរងគ្រោះថា បានឃើញឈ្មោះ [redacted] ហើម និងចោររត់ចូលក្រោមផ្ទះរបស់ឈ្មោះ [redacted] នី ស្របពេលសមត្ថកិច្ចមកដល់ក៏មានការបាញ់តគ្នាទៀត ហើយសមត្ថកិច្ចក៏បានព័ទ្ធផ្ទះសង្ស័យនោះហូតទល់ភ្លឺ ទើបចូលឆែកឆេរឃើញមានមនុស្ស ០៣ នាក់ មែន ប៉ុន្តែតំណាងមហាអយ្យការឆ្ងល់ថា ហេតុអីមិនឃើញកាំភ្លើង ឬវត្ថុតាងដែកស្បែងដែលយកទៅគាស់ទ្វារ និងវាយជនរងគ្រោះ គឺនេះជាភស្តុតាងដ៏សំខាន់សម្រាប់ដាក់ទោសលើជនណាម្នាក់ ហើយសមត្ថកិច្ចត្រូវស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយ ប៉ុន្តែក្នុងសំណុំរឿងនេះ មិនឃើញមានវត្ថុតាងទាំងអស់នោះទេ ហើយពេលនេះ ដើមបណ្តឹងក៏មិនបានចូលរួមសវនាការដើម្បីឲ្យតំណាងមហាអយ្យការសួរសំណួរខ្លះ គឺយើងមើលតែចម្លើយដែលមានក្នុងសំណុំរឿងតែប៉ុណ្ណោះ ហេតុដូច្នេះ ក្នុងរឿងនេះមានវិមតិសង្ស័យជាច្រើន អញ្ចឹងតំណាងមហាអយ្យការសូមឲ្យក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

**-លោក [redacted] ហូឡាយ** មេធាវីការពារជនជាប់ចោទសន្និដ្ឋានថា ខ្លួនសូមសង្ខេបនូវអង្គហេតុខ្លីៗ ដូចតទៅ ៖

កាលពីថ្ងៃទី ០១-៦-២០១០ កូនក្តីខ្លួនឈ្មោះ [redacted] រ៉េត បានធ្វើដំណើរពីភ្នំពេញទៅលេងឪពុកនៅភូមិព្រៃឆ្លូង តែពេលទៅដល់ឪពុកមិននៅទេ ឈ្មោះ [redacted] រ៉េត ក៏បានបន្តដំណើរពីភូមិព្រៃឆ្លូងទៅលេងផ្ទះប្អូនស្រីនៅភូមិផាត់សណ្តោងវិញ ដោយមានដឹកប្រពន្ធ និងកូនខ្ចីទៅជាមួយផង ពេលទៅដល់ផ្ទះប្អូនស្រី គឺម៉ោង ៥.០០ ល្ងាច ហើយក៏បានអង្គុយលេង និងមើលទូរទស្សន៍

រឿងអ្វីខុងរហូតដល់ចប់មួយរឿងក៏ចេញទៅឆ្លុះកង្កែបនៅវាលក្រោយផ្ទះរយៈពេលកន្លះម៉ោង ទើបវិលមកផ្ទះមើលទូរទស្សន៍រហូតដល់ម៉ោងប្រហែល ១០ ឬ ១១ យប់ ក៏ដេករហូតទល់ភ្លឺ លុះព្រឹកឡើងនគរបាលបានហៅមកសាកសួរ និងបញ្ជូនមកឃុំខ្លួនតែម្តង ។ ក្នុងរឿងនេះ បើកូនក្តីខ្លួនឈ្មោះ [redacted] រ៉េត មានបំណងប្លន់ផ្ទះអ្នកជិតខាងមែន គឺមិនដឹកប្រពន្ធដែលមានកូនខ្ចីទៅស្នាក់នៅផ្ទះជាប់កន្លែងកើតហេតុនោះទេ ព្រោះយើងដឹងហើយថា ក្រោយពេលប្លន់មិនដឹងមានរឿងអីកើតឡើងទេ ហេតុអីក៏មិនដឹកប្រពន្ធទៅស្នាក់នៅឆ្ងាយប្រហែល ១ គ.ម ដើម្បីងាយស្រួលរត់គេចខ្លួនប្រសិនបើកូនក្តីខ្លួនមានចេតនាប្លន់មែននោះ ។ ម៉្យាងទៀតកូនក្តីខ្លួនមិនត្រូវទៅពេលថ្ងៃទេ គឺត្រូវទៅពេលយប់ហើយ បើទៅពេលថ្ងៃ ធ្វើឲ្យគេស្គាល់មុខ និងមានការសង្ស័យ រីឯកន្លែងប្លន់ គឺប្លន់ផ្ទះជាប់គ្នាទៀត ចំណែកចម្លើយជនរងគ្រោះឆ្លើយនៅនគរបាលវិញ មិនអាចឲ្យជឿបានឡើយពីព្រោះឈ្មោះ [redacted] ចាន់ទី ឆ្លើយថា អាម្នាក់សម្បុរខ្មៅ មានមាឌក្រអាញ អាម្នាក់សម្បុរខ្មៅ មានមាឌធំ ហើយឥឡូវសូមឲ្យលោកព្រះរាជអាជ្ញា និងក្រុមប្រឹក្សាពិនិត្យមើលកូនក្តីខ្លួន តើមានសម្បុរខ្មៅមាឌក្រអាញ ឬមាឌធំមែនឬទេ? និងម៉្យាងទៀតជនរងគ្រោះឆ្លើយថា ឃើញជនល្មើសរត់ចូលក្រោមផ្ទះដែលជាទីងងឹត គឺមិនពិតទេ ព្រោះថា នៅទីភ្លឺមិនអាចមើលទៅទីងងឹតឃើញទេ មានតែនៅទីងងឹតទេ ដែលអាចមើលមកទីភ្លឺឃើញ ។ ចំណែកវត្ថុតាងក៏មិនឃើញមានដែរ ក្នុងរឿងនេះ ហើយការឆ្លើយរបស់ជនរងគ្រោះ គឺឆ្លើយតម្រូវតាមរូបរាងកូនក្តីខ្លួន ដែលមើលឃើញកាលពីពេលថ្ងៃតែប៉ុណ្ណោះ ហេតុដូច្នេះ ខ្លួនសូមបដិសេធចោលចំណុចដែលថា មើលឃើញកូនក្តីខ្លួនរត់ចូលក្រោមផ្ទះ និងចំណុចប្រឡាក់ឈាម ដែលជនរងគ្រោះថា ជាឈាមគាត់ តែកូនក្តីខ្លួនថាជាឈាមកង្កែប ហើយយើងក៏មិនបានធ្វើកោសលវិច័យលើឈាមនោះដែរ មិនដឹងថា ជាឈាមអីយោងតាមមាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានភាពចាំបាច់ កាលណាមានវត្ថុមួយមិនច្បាស់លាស់ គឺសមត្ថកិច្ច ឬតុលាការត្រូវធ្វើកោសលវិច័យ តែចំពោះឈាមនោះ មិនមានធ្វើកោសលវិច័យទេ ដូច្នេះ ពុំមានភស្តុតាងគ្រប់គ្រាន់ចោទលើកូនក្តីខ្លួនឡើយ ផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អញ្ចឹងសូមឲ្យក្រុមប្រឹក្សាមេត្តាសម្រេចលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនទាំង ២ នាក់ ឲ្យមានសេរីភាពឡើងវិញ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍យល់ឃើញថា</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៩ ចុះថ្ងៃទី ២៨-៦-២០១១ របស់ឈ្មោះ [redacted] រ៉េត និងឈ្មោះ [redacted] ហើម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩ "ក" ព្រ.ទ ចុះថ្ងៃទី ១០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៧៣, មាត្រា ៣៧៥, មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃ



Scanned with CamScanner

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសាលាឧទ្ធរណ៍ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ២៩-៨-២០១១ របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះបាន ។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] វ៉េត និងឈ្មោះ ជៀម ហើម បានឆ្លើយបដិសេធថា ពួកខ្លួនមិនបានប្រព្រឹត្តអំពើប្លន់ដូចការចោទប្រកាន់ទេ ។ នៅថ្ងៃកើតហេតុពួកខ្លួនពីរនាក់បងប្អូនទៅចាក់កង្កែប, ពេលចាក់កង្កែបរួចហើយ ពួកខ្លួនក៏ត្រឡប់មកផ្ទះវិញ។ ចំពោះឈាមដែលស្រក់នៅលើជើង គឺជាឈាមកង្កែប ហើយចម្លើយរបស់ជនរងគ្រោះថា ខ្លួនបានវាយនោះគឺជាចម្លើយទម្លាក់កំហុស ព្រោះគ្រួសារខ្លួនធ្លាប់មានទំនាស់នឹងគ្នារឿងផ្លូវដើរ ។ ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់នេះ គឺជាចម្លើយដែលឆ្លើយដោះសារ ព្រោះថា ជនជាប់ចោទឈ្មោះ ជៀម ហើម ពេលប្រព្រឹត្តល្មើសត្រូវបានជនរងគ្រោះស្គាល់ ហើយម៉្យាងទៀតពេលសមត្ថកិច្ចចុះទៅដល់កន្លែងកើតហេតុ ជនជាប់ចោទបានបាញ់រះមកលើសមត្ថកិច្ច រួចរត់ឡើងលើផ្ទះ [redacted] នី លុះព្រឹកឡើងសមត្ថកិច្ចក៏ចុះទៅឆែកឆេរ ហើយឃាត់ឈ្មោះ [redacted] វ៉េត និងឈ្មោះ [redacted] ហើម ។

៣-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វ៉េត និងឈ្មោះ [redacted] ហើម ពីបទ ប្លន់ប្រព្រឹត្តនៅភូមិផាត់សណ្តោង ឃុំញ្ញៅ ១ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង កាលពីថ្ងៃទី ០២-៦-១០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤-ដោយទណ្ឌកម្មនៃបទល្មើស ប្លន់ ក្នុងមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មានកម្រិតទណ្ឌកម្មរយៈពេលពី ០៥ ឆ្នាំ ទៅ ១០ ឆ្នាំ ហើយទណ្ឌកម្មនៃបទល្មើស លួចក្នុងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មានកម្រិតទណ្ឌកម្មពី ០៣ ឆ្នាំ ទៅ ១០ ឆ្នាំ ឃើញថា ទណ្ឌកម្មក្នុងបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌចែងអំពីទោសដែលស្រាលជាងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដូច្នេះ ដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ គប្បីសាលាឧទ្ធរណ៍យកបទបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌមកអនុវត្តចំពោះអំពើដែលជនជាប់ចោទបានប្រព្រឹត្ត ផ្អែកតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ។

៥-សំអាងហេតុ និសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ១៩ "ក" ព្រ.ទ ចុះថ្ងៃទី ១០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង មានមូលហេតុត្រឹមត្រូវ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះ ទុកជាបានការ លើកលែងតែចំណុចទី ២ នៃសាលក្រមនេះ ត្រូវកែប្រែ ។

៦-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទមិនសារភាព ហើយវត្ថុតាងដូចជាកាំភ្លើង, ដែកស្បែង, ពិល មិនបានរឹបអូស ដូច្នេះ មានវិមតិសង្ស័យជាច្រើន ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

៧-មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយរឿងនេះ មានវិមតិសង្ស័យជាច្រើន ដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

៨-ជនជាប់ចោទទាំងពីរនាក់និយាយសម្តីចុងក្រោយ សុំឲ្យក្រុមប្រឹក្សាដោះលែងពួកខ្លួន។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៩ ចុះថ្ងៃទី ២៨-៦-២០១១ របស់ឈ្មោះ [redacted] រ៉េត និងឈ្មោះ [redacted] ហើម ទុកជាត្រឹមត្រូវតាមច្បាប់។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] រ៉េត និងឈ្មោះ [redacted] ហើម ពីបទ ប្លន់ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទល្មើសលួចដោយប្រើហិង្សា បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ១០, មាត្រា ៣៥៣, និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩ "ក" ព្រ.ទ ចុះថ្ងៃទី ១០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ លើកលែងតែចំណុចទី ២ នៃសាលក្រមនេះ ត្រូវកែប្រែពីការផ្តន្ទាទោសលើឈ្មោះ [redacted] រ៉េត និងឈ្មោះ [redacted] ហើម ដាក់ពន្ធនាគាររយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ មកដាក់ពន្ធនាគាររយៈពេល ០៤ (បួន) ឆ្នាំ វិញ ពីបទ លួចដោយប្រើហិង្សា បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ១០, មាត្រា ៣៥៣, និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤-បន្តការឃុំខ្លួនលើឈ្មោះ [redacted] រ៉េត និងឈ្មោះ [redacted] ហើម តាមកំណត់ច្បាប់ ។

៥-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី ២៦-៣-២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩-៤-២០១២ ។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 06 ខែ 3 ឆ្នាំ ២០១៤

| បានឃើញ | ក្រឡាបញ្ជី |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | Chetta |
| [redacted] | [redacted] |

១៤៥